**សេចក្តីប្រកាសព័ត៌មាន**

*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧*

# លទ្ធផលស្តីពីជំនួបសវនការរវាង ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងគណៈប្រតិភូសមាជិកសភាសហភាពអឺរ៉ុបទទួលបន្ទុកទំនាក់ទំនងអាស៊ីអាគ្នេយ៍ និងអាស៊ាន

នាថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ វេលាម៉ោង ១០:៤០ នាទីព្រឹក នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូសមាជិកសភាសហភាពអឺរ៉ុបទទួលបន្ទុកទំនាក់ទំនងអាស៊ីអាគ្នេយ៍ និងអាស៊ាន ដោយផ្តោត លើការផ្លាស់ប្តូរទស្សនៈស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងការផ្លាស់ប្តូរទស្សនៈស្តីពីកម្មវិធីកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានធ្វើការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់គណៈប្រតិភូសមាជិកសភាសហភាពអ៊ឺរ៉ុបទទួលបន្ទុកទំនាក់ទំនងអាស៊ីអាគ្នេយ៍ និងអាស៊ាន ដែលអញ្ជើញមកធ្វើបេសកកម្មនៅប្រទេសម្ពុជា ចាប់ពីថ្ងៃទី ៣០-៣១ ខែ តុលា ឆ្នាំ ២០១៧ និងថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងកិច្ចសហប្រត្តិការដ៏ល្អប្រសើររវាងសហភាពអឺរ៉ុប និង រាជរដ្ឋាភិបាលកម្ពុជា ។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី** បានជម្រាបពីស្ថានភាពសេដ្ឋកិច្ច នៃប្រទេសកម្ពុជា ដែលកំពុងមានការអភិវឌ្ឍពីមួយឆ្នាំទៅមួយឆ្នាំ ដោយខិតខំរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបន្តតម្រង់ឆ្ពោះទៅរកចក្ខុវិស័យ ឆ្នាំ ២០៣០ ដើម្បីប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ។ សមិទ្ធផលទាំងនេះ កើតចេញពីការខិតខំដោយកម្ពុជាខ្លួនឯងផង និងដោយមានកិច្ចសហប្រតិបត្តិការល្អពីប្រទេសជាដៃគូ រាប់ទាំងសហភាពអ៊ឺរ៉ុបផង ដែលបានពង្រឹងកិច្ចសហប្រតិបត្តិការតាមរយៈជំនួយ និងការអនុគ្រោះលើវិស័យពាណិជ្ជកម្ម ដែលនាំឱ្យមានគោលការណ៍អនុគ្រោះ ជាដើម។

ឆ្លើយតបទៅនឹងទិដ្ឋភាពទាំងនេះ លោក Werner Langen ប្រធានគណៈកម្មាធិការកិច្ចការសេដ្ឋកិច្ច និងរូបិយវត្ថុរបស់សហភាពអឺរ៉ុប បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដែលរូបឯកឧត្តម ព្រមទាំងគណៈប្រតិភូបានឃើញជាក់ច្បាស់នឹងភ្នែក ក្នុងពេលបំពេញទស្សនកិច្ចនៅកម្ពុជានាពេលនេះ ។ ដោយឡែក គណៈប្រតិភូមានបំណងចង់ស្វែងយល់ពីកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិ-

បាល ដែលបានខិតខំអនុវត្តកន្លងមក ហើយឯកឧត្តមក៏បានមើលឃើញអំពីភាពឈានមុខរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរហូតដល់សម្រេចបានផ្លែផ្កាដ៏ធំធេងមកដល់ពេលនេះ ខណៈពេលដែលកម្មវិធីកែទម្រង់លើវិស័យផ្សេងៗទៀតកំពុងអនុវត្ត ។

ក្នុងទស្សនៈនេះ **ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់បន្ថែមថា ពិតណាស់សមិទ្ធផលផ្លែផ្កាទាំងនេះ គឺមិនអាចកាត់ផ្តាច់ចេញពីកម្មវិធិកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានឡើយ ដែលបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចសន្សំថវិកា និងវិភាជថវិកាទៅតាមក្រសួង-ស្ថាប័នទីមួយៗចំគោលដៅ និងតាមវិស័យអាទិភាព ដែលរាជរដ្ឋាភិបាលបានផ្តោតយកចិត្តទុកដាក់ ។ ជាក់ស្តែង, ថវិកាសម្រាប់វិស័យអប់រំត្រូវបានបង្កើន ចំនួនជិត ៣ ដង ក្នុងអណត្តិទី ៥ នេះ ក្នុងពេលដែលកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល និងក្រសួងមួយចំនួនទៀតដែលស្ថិតក្នុងវិស័យសង្គមកិច្ចក៏ត្រូវបានបង្កើនផងដែរ ។ លើសពីនេះ វិស័យហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងទេសចរណ៍ ក៏កំពុងត្រូវបានកែលម្អតាមរយៈ ការបង្កើតនូវគោលនយោបាយ និងកម្មវិធីជាក់លាក់ថ្មីៗជាបន្តបន្ទាប់ ។ ជាមួយគ្នានេះដែរ ក្នុងពេលដែលកម្ពុជាបានរំដោះខ្លួនចេញពីប្រទេសដែលមានចំណូលកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបភាពអាស្រ័យនឹងហិរញ្ញប្បទានក្រៅប្រទេស ចំពោះថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលក៏ត្រូវបានកាត់បន្ថយដែលនេះបញ្ជាក់ពីភាពចាស់ទំនៃសេដ្ឋកិច្ចកម្ពុជា ។

គណៈប្រតិភូ បានសម្តែងការអបអរសាទរជាមួយរាជរដ្ឋាភិបាលកម្ពុជាលើចក្ខុវិស័យ និងការដ្ឋានកែទម្រង់លើវិស័យសំខាន់នានា ហើយសន្យានឹងបន្តគាំទ្រ និងជួយរាជរដ្ឋាភិបាល សម្រាប់ចក្ខុវិស័យដែលបានដាក់ចេញ ជាពិសេសលើកិច្ចការកែទម្រង់ ការបន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងកាត់បន្ថយភាពក្រីក្រ ដែលជាឧត្តមប្រយោជន៍សម្រាប់សង្គមកម្ពុជា ។

កិច្ចប្រជុំបានបញ្ចប់ដោយបរិយាកាសស្និតស្នាល និងកិច្ចសហប្រតិបត្តិការល្អ ។